# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ២៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា ២ និង មាត្រា ៣ នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណៈការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**មាត្រា មួយ.-**

មាត្រា ២ និង មាត្រា ៣ នៃអនុក្រឹត្យលេខ ៦៤ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ត្រូវបានកែសម្រួលដូចតទៅ ៖

**មាត្រា ២ ថ្មី.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| - ឯកឧត្តម **សុខ អាន** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - ឯកឧត្តម **គាត ឈន់** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - ឯកឧត្តម **ស៊ុន ចាន់ថុល** | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធានអចិន្ត្រៃយ៍ |
| - ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជារដ្ឋមន្ត្រីទទួលបន្ទុកការងារ AMBDC | សមាជិក |

- រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ — សមាជិក
- អនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងផែនការ — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ — សមាជិក
- អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ — សមាជិក
- តំណាង គណៈកម្មាធិការព្រំដែន — សមាជិក
- អគ្គលេខាធិការរង អាជ្ញាធរកំចាត់មីនកម្ពុជា — សមាជិក
- អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ — សមាជិក
- ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា — សមាជិកអចិន្ត្រៃយ៍

**មាត្រា ៣ ថ្មី.-**

គណៈកម្មាធិការជាតិ គំរោងផ្លូវដែកសិង្ហបុរី-គុនមីញ មានក្រុមការងារបច្ចេកទេសមួយជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោម :

- ប្រធានអគ្គនាយក រាជាយស្ម័យយានកម្ពុជា — ប្រធាន
- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ — អនុប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — អនុប្រធាន
- ប្រធាននាយកដ្ឋាន គមនាគមន៍ និងប្រៃសណីយ៍ ទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក
- ប្រធាននាយកដ្ឋានអាស៊ាន ទីស្តីការគណៈរដ្ឋមន្ត្រី — សមាជិក

- ប្រធាននាយកដ្ឋាន ផែនការ-ស្ថិតិ ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- ប្រធាននាយកដ្ឋាន ទំនាក់ទំនងអន្តរជាតិ ក្រសួងផែនការ សមាជិក
- តំណាង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាង ក្រសួងបរិស្ថាន សមាជិក
- តំណាង ក្រសួងការពារជាតិ សមាជិក
- តំណាង ក្រសួងមហាផ្ទៃ សមាជិក
- នាយក ផ្លូវ ស្ពាន អាគារ រាជាយស្វ័យយានកម្ពុជា សមាជិក
- អភិបាលស្រុកពាក់ព័ន្ធ សមាជិក
- នាយករងរដ្ឋបាលទទួលបន្ទុកការិយាល័យផែនការ-ស្ថិតិ រអយក លេខាធិការអចិន្ត្រៃយ៍

**មាត្រា ពីរ.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា បី.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ គណៈកម្មាធិការព្រំដែន អាជ្ញាធរកំចាត់មីនកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលខេត្ត-ក្រុងពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោក ដែលមានចែងក្នុងមាត្រា ២ថ្មី និង មាត្រា ៣ថ្មី ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា បី
- ឯកសារ- កាលប្បវត្តិ